ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីថ្លែងការណ៍
# របស់រាជរដ្ឋាភិបាលកម្ពុជា

តាមសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានស្នើសុំតុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេ ចង្អុលអំពីវិធានការបន្ទាន់ដែលជាជំហានទី ១ នៃការបកស្រាយសាលក្រម ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៦២ ទាក់ទងនឹងប្រាសាទព្រះវិហារ តុលាការនេះបានចេញនូវសេចក្តីសំរេចរបស់ខ្លួន នៅថ្ងៃ ច័ន្ទ ទី ១៨ កក្កដា ឆ្នាំ ២០១១ ដូចតទៅ ÷

**តុលាការបាន** :

ក. ជាឯកច្ឆ័ន្ទ

ច្រានចោលនូវសំណើរបស់ព្រះរាជាណាចក្រថៃឡង់ដ៏ ដែលបានស្នើសុំដកសំណើរបស់ព្រះរាជាណាចក្រ - កម្ពុជា កាលពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ ចេញពីរបៀបវារៈរួមរបស់តុលាការ

ខ. ចង្អុលនូវវិធានការបណ្តោះអាសន្នដូចតទៅ :

១- ដោយសំឡេង ១១ ទល់នឹង ៥

ភាគីទាំងពីរត្រូវដកជាបន្ទាន់នូវបុគ្គលិកយោធា ដែលមានវត្តមានបច្ចុប្បន្ននៅក្នុងតំបន់គ្មានយោធាជាបណ្តោះអាសន្នដូចមានចែងក្នុងកថាខ័ណ្ឌ ៦២ នៃសេចក្តីសំរេចនេះ និងទប់ស្កាត់មិនអោយមានវត្តមានយោធាក្នុងតំបន់នោះ និងមិនអោយមានសកម្មភាពប្រដាប់អាវុធណាមួយតម្រង់ទៅកាន់តំបន់នោះឡើយ ។

២- ដោយសំឡេង ១៥ ទល់នឹង ១

ប្រទេសថៃមិនត្រូវរារាំងការចេញចូលដោយសេរីរបស់កម្ពុជាទៅកាន់ប្រាសាទព្រះវិហារ ឬការផ្គត់ផ្គង់ស្បៀងអាហារចំពោះបុគ្គលិកដែលមិនមែនយោធានៅក្នុងប្រាសាទឡើយ ។

៣- ដោយសំឡេង ១៥ ទល់នឹង ១

ភាគីទាំងពីរត្រូវបន្តកិច្ចសហប្រតិបត្តិការដែលគេបានព្រមព្រៀងនៅក្នុងក្រមខ័ណ្ឌអាស៊ាន និងជាពិសេសអនុញ្ញាតអោយអ្នកសង្កេតការណ៍ដែលត្រូវបានតែងតាំងដោយអង្គការនេះ អោយចូលទៅកាន់តំបន់គ្មានយោធាជាបណ្តោះអាសន្ន ។

៤- ដោយសំឡេង ១៥ ទល់នឹង ១

ភាគីទាំងពីរត្រូវតែអត់ធ្មត់ មិនធ្វើនូវសកម្មភាពណាដែលអាចនាំអោយជម្លោះដែលបានស្នើអោយតុលាការដោះស្រាយនោះមានសភាពកាន់តែធ្ងន់ធ្ងរ ឬ រីកធំឡើង ឬ ធ្វើអោយជម្លោះនោះកាន់តែពិបាកដោះស្រាយថែមទៀត ។

គ. ដោយសំឡេង ១៥ ទល់នឹង ១

បានសំរេចអោយភាគីនីមួយៗ ត្រូវផ្តល់ពតិមានដល់តុលាការទាក់ទងទៅនឹងការអនុវត្តន៍ប្រតិបត្តិរបស់ខ្លួនឆ្លើយតបនឹងវិធានការបណ្តោះអាសន្នខាងលើនេះ ។

ឃ. ដោយសំឡេង ១៥ ទល់នឹង ១

បានសំរេចថា : រហូតដល់ពេលតុលាការចេញនូវសេចក្តីសំរេចរបស់ខ្លួន ឆ្លើយតបនឹងសំណើសុំការបកស្រាយនោះ តុលាការនឹងនៅតែបន្តតាមដានកិច្ចការទាំងនេះដែលជាកម្មវត្ថុនៃសេចក្តីសំរេចនេះ ។

រាជរដ្ឋាភិបាលកម្ពុជា សូមគាំទ្រទាំងស្រុងនូវសេចក្តីសំរេចខាងលើនេះ របស់តុលាការយុត្តិធមិអន្តរជាតិទីក្រុងឡាអេ ដែលជាការឆ្លើយតបយ៉ាងពេញទំហឹងទៅនឹងការចង់បានរបស់កម្ពុជា ក្នុងការធ្វើអោយតំបន់ប្រាសាទព្រះវិហារមានសន្តិភាព មានអ្នកសង្កេតការណ៍អាស៊ានចូលមកក្នុងតំបន់គ្មានកងទ័ពជាបណ្តោះអាសន្ន និងមានសកម្មភាពផ្នែកស៊ីវិលជាប្រក្រតី ។

រាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមថា រាជរដ្ឋាភិបាលថៃឡង់ដ៏នឹងទទួលយក ព្រមទាំងគោរពតាមសេចក្តីសំរេចដ៏ត្រឹមត្រូវខាងលើនេះ របស់តុលាការអន្តរជាតិ ។

រាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវអោយអ្នកសង្កេតការណ៍ឥណ្ឌូនេស៊ី ដែលគ្រប់ប្រទេសអាស៊ានទាំង ១០ បានអនុម័តកន្លងទៅ និងដែលជាការតម្រូវនៃសេចក្តីសំរេចខាងលើនេះរបស់តុលាការអន្តរជាតិនោះ មកបំពេញបេសកកម្មរបស់ខ្លួននៅតំបន់គ្មានកងទ័ពជាបណ្តោះអាសន្នអោយបានឆាប់បំផុតដែលអាចធ្វើទៅបាន ។ កម្ពុជាត្រៀមជាស្រេចដើម្បីស្វាគមន៍និងសំរួលបេសកកម្មគ្រប់បែបយ៉ាងរបស់អ្នកសង្កេតការណ៍ទាំងនោះ ។

រាជរដ្ឋាភិបាលកម្ពុជា សូមថ្លែងនូវអំណរគុណ និងសូមសរសើរដ៏ស្មោះចំពោះគណៈប្រតិភូកម្ពុជាដែលដឹកនាំដោយឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលបានតស៊ូប្រឹងប្រែងសំរេចបានជោគជ័យដ៏ត្រចះត្រចង់ជូនជាតិមាតុភូមិកម្ពុជា ។

*ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១*